**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការចរចាជុំទីពីរ លើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងសាធារណជនទាំងអស់មេត្តាជ្រាបថា នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ កម្ពុជា និងចិនបានបញ្ចប់ការចរចាជុំទីពីរ លើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី តាមរយៈកិច្ចប្រជុំតាមវីដេអូអនឡាញ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ សុភ័ក្ត្រ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មកម្ពុជា និង ឯកឧត្តម យ៉ាង ចឹងវ៉ី** (Yang Zhengwei) **អគ្គនាយករងក្រសួងពាណិជ្ជកម្មចិន។** ការចរចាជុំទីពីរនេះជាការចរចាបន្តពីជុំទីមួយ ដែលបានធ្វើឡើងកាលពីថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២០កន្លងមក នៅទីក្រុងប៉េកាំង ប្រទេសចិន ដើម្បីពិនិត្យវឌ្ឍនភាពការងារតាមក្រុមការងារតូចៗ និងដោះស្រាយបញ្ហាសេសសល់មួយចំនួន។

ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិននេះ គឺជាគំនិតផ្តួចផ្តើម និងជាអាណត្តិដែលបានផ្តល់ឱ្យដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **ឯកឧត្តម លី ខឺឈាំង** (Li Keqiang) **នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន** នៅក្នុងជំនួបទ្វេភាគីនាថ្ងៃទី២០-២៣ ខែមករា ឆ្នាំ២០១៩ នៅទីក្រុងប៉េកាំង ក្នុងគោលដៅពង្រីកការធ្វើពាណិជ្ជកម្ម វិនិយោគ សេវា និងកិច្ចសហប្រតិបត្តិការឲ្យកាន់តែស៊ីជម្រៅ សម្រាប់ជាឧត្តមប្រយោជន៍នៃប្រជាជនរបស់ប្រទេសទាំងពីរ។

ក្នុងការចរចាជុំទីពីរ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលសម្រេចបានដោយក្រុមការងារចរចាទាំង ១០ ក្រុម ដែលទទួលបានតាមរយៈការផ្លាស់ប្តូរយោបល់ និងចរចាយ៉ាងសកម្ម តាមមធ្យោបាយអនឡាញ ទោះបីប្រទេសទាំងពីរកំពុងមមាញឹកក្នុងការអនុវត្តវិធានការការពារ និងប្រយុទ្ធប្រឆាំងនឹងការរាតត្បាតជំងឺកូវីដ-១៩ ក៏ដោយ។ ក្រុមការងារចរចានៃប្រទេសទាំងពីរបានឯកភាពគ្នាលើជំពូកមួយចំនួននៅក្នុងជុំចរចាទីពីរនេះ ដូចជាជំពូកទាក់ទងនឹងកិច្ចសហប្រតិបត្តិការវិនិយោគ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស កិច្ចសហប្រតិបត្តិការគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ក្នុងនោះដែរ ក្រុមការងារបានចរចា និងឯកភាពជាគោលការណ៍លើបញ្ហានានាដែលមិនទាន់បានដោះស្រាយមួយចំនួន ព្រមទាំងបានកំណត់គោលការណ៍ និងដាក់ទិសដៅឱ្យក្រុមការងារតូចៗទាំង១០ យកទៅពិភាក្សាបន្ត ហើយរាយការណ៍ឱ្យប្រធានក្រុមចរចា មិនឱ្យលើសពីពាក់កណ្តាលខែឧសភា ឆ្នាំ២០២០ ដើម្បីប្រធានក្រុមចរចានៃភាគីនីមួយៗ យកទៅពិភាក្សាផ្ទៃក្នុងរៀងៗខ្លួន សំដៅឈានដល់ការឯកភាពគ្នាទាំងស្រុង និងបញ្ចប់ការចរចាកិច្ចព្រមព្រៀងនេះ នៅខែមិថុនា ឆ្នាំ២០២០ តាមការគ្រោងទុក។

ថ្ងៃសុក្រ ៣កើត ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

ក្រសួងពាណិជ្ជកម្ម

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd.. Phum Teuk Thla. Sangkat Teuk Thla. Khan Sen Sok. Phnom Penh. Kingdom of CAMBODIA Phone/Fax: (855) 23 866 469